# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៧៧

របាយការណ៍គិតត្រឹមថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០២១ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗចាប់តាំងពីសប្តាហ៍មុន

- ករណីវិជ្ជមានវីរុសកូវីដ-១៩ សរុបចំនួន ៩៤ និងករណីស្លាប់ចំនួន ២០ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល១៤ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោម ៩៤ ករណីនោះ មានករណីនាំចូលចំនួន៣៥ ឬ៣៧ភាគរយ និងករណីឆ្លងក្នុងស្រុកចំនួន ៥៩ ឬ ៦៣ ភាគរយ។
- ករណីសរុបទាំងអស់ចំនួន ១២០.៤៦៤ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០០៩ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះ ១១៦.៨៧៤ករណី បានជាសះស្បើយ។ ករណីនាំចូលពីក្រៅប្រទេសសរុបមានចំនួន ១៩.៨៨៨ ឬស្មើនឹង ១៦.៥ ភាគរយនៃករណីជំងឺកូវីដ-១៩ ទាំងអស់។
- ចាប់តាំងពីខែមករា ឆ្នាំ២០២០ មក បុគ្គលសរុបចំនួន ១.៧៧៩.០១៣នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Real-Time Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៤.៩ ភាគរយ។ ជាសរុប គិតត្រឹមថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០២១ ចំនួនតេស្ត ២.៩៧៣.៣៩៣ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍។
- **ការតាមដានជំងឺ:** គិតត្រឹមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ករណីវិជ្ជមានវីរុសកូវីដ-១៩ប្រភេទបំប្លែងខ្លួនថ្មីអូមីក្រុងសរុបចំនួន៣១ ត្រូវបានរកឃើញពេលអ្នកជំងឺមកដល់ព្រំដែនកម្ពុជាដែលនៅក្នុងនោះមាន៩ករណីមិនមានចេញរោគសញ្ញា។ ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោកបានធ្វើការវាយតម្លៃរួមគ្នាមួយអំពីអូមីក្រុង និងវិធានការទប់ស្កាត់នាពេលបច្ចុប្បន្ន។ អង្គការសុខភាពពិភពលោកបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួងសុខាភិបាលនៅក្នុងការពង្រឹងយុទ្ធសាស្ត្រតាមដានជំងឺសម្រាប់ជំងឺរាតត្បាតកូវីដ-១៩ ការធានឱ្យមានការត្រៀមខ្លួនរួចរាល់ ការរកឃើញករណី និងឆ្លើយតបបានឆាប់រហ័សក្នុងអំឡុងពេលនៃការបើកដំណើរការប្រទេសឡើងវិញប្រកបដោយសុវត្ថិភាព។
- **មន្ទីរពិសោធន៍:** អង្គការសុខភាពពិភពលោកកំពុងផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេសដល់ក្រសួងសុខាភិបាលស្តីពីយុទ្ធសាស្ត្រប្រមូលសំណាកសម្រាប់ការតាមដានសេណូមសាស្ត្រចំពោះវីរុសកូវីដ-១៩ រួមទាំងការដាក់បញ្ចូលការស្វែងរកមេរោគកូវីដ-១៩បំប្លែងខ្លួនថ្មីអូមីក្រុងទៅក្នុងលំហូរការងារតាមដានជំងឺសេណូមសាស្ត្របច្ចុប្បន្ន។ វិទ្យាស្ថានសុខភាពសាធារណៈ បានសហការជាមួយនឹងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អង្គការសុខភាពពិភពលោក និងដៃគូនៅក្នុងការអនុវត្តកម្មវិធីធានាគុណភាពវីរុសកូវីដ-១៩ (SARS-CoV-2 External Quality Assurance) ដើម្បីធានាគុណភាពតេស្តនៅមន្ទីរពិសោធន៍រកវីរុសកូវីដ-១៩ទាំងអស់។
- **ការចាក់វ៉ាក់សាំងកូវីដ-១៩:**
  - សម្តេចតេជោនាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ឱ្យចាក់វ៉ាក់សាំងដូសជម្រុញលើកទី២ដោយប្រើវ៉ាក់សាំងPfizer ដល់បុគ្គលិកសុខាភិបាល និងមន្ត្រីរដ្ឋាបាលជួរមុខ។
  - គិតត្រឹមថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាទទួលបានវ៉ាក់សាំងកូវីដ-១៩ចំនួន ៤១.០៩១.៦០០ ដូស
    - ចំនួន ២៨.៥០០.០០០ដូស ឬស្មើនឹង ៦៩ ភាគរយ សម្រាប់វ៉ាក់សាំងស៊ីណូវ៉ាក់ និង វ៉ាក់សាំងស៊ីណូហ្វាម តាមរយៈការបញ្ជាទិញដោយរាជរដ្ឋាភិបាលកម្ពុជាពីសាធារណរដ្ឋប្រជាមានិត្យចិន
    - ចំនួន ៨.៧១៥.០៤០ដូស ឬស្មើនឹង ២១ ភាគរយតាមរយៈជំនួយ (៨.៣០០.០០០ដូសវ៉ាក់សាំងស៊ីណូវ៉ាក់ និង វ៉ាក់សាំងស៊ីណូហ្វាម ជាជំនួយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិត្យចិន និងចំនួន ៤១៥.០៤០ដូសវ៉ាក់សាំង AstraZeneca ជាជំនួយរបស់ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស)។
    - ចំនួន ៣.៨៧៦.៥៦០ដូស ឬស្មើនឹង ១០ ភាគរយនៃវ៉ាក់សាំង AstraZeneca, Johnson & Johnson, Moderna និង Sinovac ទទួលបានតាមរយៈជំនួយពីមជ្ឈមណ្ឌលកូវ៉ាក់ (ដែលក្នុងនោះរួមមានជំនួយពីរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលសហរដ្ឋអាមេរិក រដ្ឋាភិបាលស៊ុយអែត និងរដ្ឋាភិបាលប្រទេសហូល្លង់)។
  - ចំនួន ២.៣៥០.៥៣០ដូសនៃវ៉ាក់សាំង Pfizer-BioNTech (Comirnaty) ជាជំនួយរបស់ប្រទេសអូស្ត្រាលី ត្រូវបានរំពឹងថានឹងមកដល់កម្ពុជានៅថ្ងៃទី ២៦ និង២៨ ខែធ្នូ ឆ្នាំ២០២១។
  - វ៉ាក់សាំងកូវីដ-១៩ ចំនួន ៤.៨៧០.៣៧៤ ដូសនៅសល់ក្នុងស្តុកនៅឃ្លាំងឱសថកណ្តាលរបស់ក្រសួងសុខាភិបាល។
  - សកម្មភាពចាក់វ៉ាក់សាំង កំពុងបន្តតាមរយៈការអនុវត្តយុទ្ធសាស្ត្រចាក់វ៉ាក់សាំងដល់អ្នកដែលពិបាកចូលទៅដល់ដើម្បីជម្រុញឱ្យពួកគាត់ទទួលបានការចាក់វ៉ាក់សាំងពេញលេញជាពិសេសក្នុងចំណោមក្រុមប្រជាជនងាយរងគ្រោះ (ដូចជាមនុស្សវ័យចាស់ អ្នកដែលមានជំងឺប្រចាំកាយ ស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងបំបៅដោះកូន អ្នកមានផ្ទុកវីរុស និងមានជំងឺអេដស៍ អ្នកមានពិការភាព និងជនទេសន្តរប្រវេសន៍) និងអ្នកដែលបានជាសះស្បើយពីជំងឺកូវីដ-១៩។ សកម្មភាពទាំងនេះ ត្រូវបានអនុវត្តនៅ៖ ទី១កន្លែងចាក់វ៉ាក់សាំងដែលមាននៅតាមមូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែក) ទី២ការចាក់វ៉ាក់សាំងចល័ត និងទី៣ការចាក់វ៉ាក់សាំងចល័តដែលត្រូវបានដាក់បញ្ចូលជាមួយនឹងការចុះចាក់វ៉ាកសាំងជាប្រចាំនៅតាមមូលដ្ឋាន។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- **ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍**
  - មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព បានបញ្ចប់ជំហ៊ានដំបូងនៃសកម្មភាពចូលរួមរបស់សហគមន៍នៅក្នុងខេត្តចំនួន៩។ មជ្ឈមណ្ឌលបានរៀបចំរបាយការណ៍ និងអនុសាសន៍រួច និងបានចែករំលែកជាមួយនឹងអង្គការសុខភាពពិភពលោករួចហើយ។
  - ផែនការប្រាស្រ័យទាក់ទងយុទ្ធសាស្រ្តមួយ ត្រូវបានរៀបចំស្របទៅតាម យុទ្ធសាស្រ្តស្តីពីការរស់នៅបែបគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព កំពុងដឹកនាំការរៀបចំផែនការប្រាស្រ័យទាក់ទងនេះ ដោយទទួលបានការគាំទ្រពីអង្គការសុខភាពពិភពលោក។ ផែនការនេះ នឹងត្រូវចែករំលែកនៅពេលផែនការនេះជាភាសាខ្មែរត្រូវបានរៀបចំរួចរាល់។
  - សារសំខាន់ៗពីអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិចត្រូវបានចែករំលែកជាមួយមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ដើម្បីពិនិត្យមើល និងកែសម្រួលតាមបរិបទកម្ពុជា និងសម្រាប់បង្កើនការយល់ដឹងនៅកម្ពុជា។
  - សារសំខាន់ស្តីពីការចាក់វ៉ាក់សាំងសម្រាប់ស្រ្តីមានផ្ទៃពោះ និងស្រ្តីកំពុងបំបៅដោះកូន កំពុងត្រូវបានត្រួតពិនិត្យសម្រាប់ប្រើនៅក្នុងយុទ្ធនាការផ្សព្វផ្សាយតាមបណ្តាញហ្វេសប៊ុក។

- **អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ**
  - សម្តេចតេជោនាយករដ្ឋមន្រ្តី បានប្រកាសបញ្ចប់ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ចាប់ពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២១តទៅ គឺចាប់ពីថ្ងៃដំបូងដែលកម្ពុជាគ្មានករណីស្លាប់ដោយសារជំងឺកូវីដ-១៩ ក្រោយរយៈពេល១០ខែនៃព្រឹត្តិការណ៍សហគមន៍នេះ ក្នុងនោះមានករណីវិជ្ជមានវីរុសកូវីដ-១៩ឆ្លងសរុបចំនួន ១២០.៩២៣ និងករណីស្លាប់សរុប៣.០០៥នាក់។ ទោះជាយ៉ាងណាក្តី សម្តេចបានអំពាវឱ្យពលរដ្ឋបន្តបង្កើនការប្រុងប្រយ័ត្ន ឱ្យទៅចាក់វ៉ាក់សាំងឱ្យបានពេញលេញ និងឱ្យបន្តអនុវត្តវិធានការការពារប្រយោជន៍ដើម្បីការពារខ្លួនឯងផ្ទាល់ ការពារគ្រួសារ និងសហគមន៍ ដើម្បីចូលរួមបើកដំណើរការសេដ្ឋកិច្ច និងសង្គមឡើងវិញឱ្យបានរលូន។
  - ចាប់ពីថ្ងៃទី ២២ ដល់ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០២១ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបា និងមន្ទីរសុខាភិបាលខេត្តព្រះសីហនុរួមជាមួយនឹងការគាំទ្រពីអង្គការសុខភាពពិភពលោក បានសម្របសម្រួលសិក្ខាសាលាថ្នាក់ខេត្តមួយដើម្បីពង្រឹងប្រព័ន្ធតាមដានការអនុវត្តវិធានការសុខភាពសាធារណៈ និងសង្គម ដោយមានការចូលរួមពីមន្ទីរសុខាភិបាលខេត្តបាត់ដំបង មន្ទីរសុខាភិបាលខេត្តកែប មន្ទីរសុខាភិបាលខេត្តកោះកុង និងមន្ទីរសុខាភិបាលខេត្តសៀមរាប។ សិក្ខាកាមដែលអញ្ជើញមកពីវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល បានពិភាក្សាពីតួនាទី និងមុខងាររបស់ខ្លួន នីតិវិធីប្រតិបត្តិស្តង់ដារ និងយុទ្ធសាស្រ្តដើម្បីពង្រឹងការអនុវត្តតាមវិធានសុខភាពសាធារណៈ និងសង្គម ក៏ដូចជាការតាមដានការអនុវត្ត ជាពិសេសនៅក្នុងបិរបទនៃជំងឺកូវីដ-១៩ ដើម្បីធានាឱ្យបាននូវដំណើរការបើកអាជីវកម្ម និងសង្គមឡើងវិញប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ខណៈដែលអាចចៀសវាងខ្សែបន្ទាត់ក្រហម និងការពារប្រជាជនងាយរងគ្រោះ។

- **អន្តរាគមន៍ និងការផ្តល់សេវាសុខភាព**
  - បុគ្គលិកផ្នែកព្យាបាលជំងឺធ្ងន់ (ICU) ចំនួន ៣៨នាក់មកពីខេត្តចំនួន៩រួមមានខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តប៉ៃលិន ខេត្តកំពង់ធំ ខេត្តស្វាយរៀង ខេត្តឧត្តរមានជ័យ ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី បានបញ្ចប់ការបណ្តុះបណ្តាលរយៈពេល១០ថ្ងៃស្តីពីជំនាញគ្រប់គ្រងករណីជំងឺកូវីដ-១៩ធ្ងន់ធ្ងរ ដោយការបណ្តុះបណ្តាលត្រូវបានរៀបចំនៅក្នុងមន្ទីរពេទ្យជាតិចំនួនបីនៅរាជធានីភ្នំពេញ គឺមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត មន្ទីរពេទ្យព្រះកុសមៈ និងមណ្ឌលសុខភាពចាក់អង្រែ។
  - រហូតមកទល់នឹងពេលនេះ រាជធានី-ខេត្តទាំង ២៥ បានទទួលការបណ្តុះបណ្តាលដោយផ្ទាល់អំពីការព្យាបាលដោយប្រើអុកស៊ីហ្សែន។ ឧបករណ៍វាស់កម្រិតអុកស៊ីសែននៅក្នុងឈាមត្រូវបានចែកជូនទៅមន្ទីរពេទ្យខេត្តទាំងនោះអំឡុងពេលវគ្គបណ្តុះបណ្តាល។
  - កិច្ចពិភាក្សាប្រចាំសប្តាហ៍ស្តីពីករណីគ្លីនិកត្រូវបានរៀបចំឡើងនៅដោយមានការធ្វើបទបង្ហាញតាមអនឡាញពីមន្ទីរពេទ្យខេត្តតាកែវ និងមន្ទីរពេទ្យខេត្តព្រៃវែង។ កិច្ចពិភាក្សាបែបនេះ ជាវេទិការដ៏សំខាន់សម្រាប់បង្កើនចំណេះដឹងរបស់បុគ្គលិកសុខាភិបាលជួរមុខដែលគ្រប់គ្រងករណីនៃជំងឺកូវីដ-១៩។ មានអ្នកចូលរួមប្រមាណជា ១០០នាក់ជាមធ្យមនៅក្នុងកិច្ចពិភាក្សាដែលធ្វើឡើងតាមZoom មួយលើកៗ។
  - ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរក្សានូវការផ្តល់សេវាសុខាភិបាលជាសារវ័ន្តអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល បានសិក្សាអំពីថាតើសេវាប្រភេទណាមួយទទួលរងផលប៉ះពាល់ដោយការរាតត្បាតខ្លាំងជាងគេ និងមូលហេតុ ដើម្បីរៀបចំអន្តរគមន៍ឆ្លើយតបនឹងបញ្ហាប្រឈមដែលបានរកឃើញ។ នាយកដ្ឋានមន្ទីរ



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ពេទ្យ បានរៀបចំកិច្ចប្រជុំអនឡាញលើកទីពីរកាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២១ ដោយមានការចូលរួមពីនាយកមន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែកខេត្តព្រៃវែង។

- អនុគណៈកម្មការបច្ចេកទេស និងគ្រប់គ្រងកូវីដ-១៩ កំពុងធ្វើបច្ចុប្បន្នភាពសេចក្តីព្រៀងស្តីការគ្រប់គ្រងបែបគ្លីនិកកំណែប្រែទី៤ ដើម្បីដាក់បញ្ចូលចំណុចកែប្រែមួយចំនួនចាប់តាំងពីពេលដែលឯកសារនេះត្រូវត្រូវបានចេញផ្សាយជាផ្លូវការតាំងពីខែសីហាឆ្នាំ២០២១មក។
- កម្មវិធីបង្ហាត់បង្ហាញ និងកិច្ចពិភាក្សាបែបគ្លីនិកប្រចាំសប្តាហ៍ កំពុងដំណើរការ ដើម្បីពង្រឹងសមត្ថភាពបុគ្គលិកសុខាភិបាល។ កិច្ចប្រជុំលើកក្រោយ នឹងត្រូវធ្វើនៅមន្ទីរពេទ្យខេត្តកណ្តាលដោយមានការបង្ហាញករណីសិក្សាបែបគ្លីនិកផងដែរ។

## ក្រាហ្វិកទី១. ខ្សែកោងអេពីដេមីសាស្ត្រនៃករណីជំងឺកូវីដ-១៩ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ២០២១*




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## តារាងទី១. តារាងសង្ខេបអំពីសូចនាករកូវីដ-១៩

| | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
|---|---|---|---|---|
| **បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩** | 27,632<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | 94<br>ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | 20<br>ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | 70<br>ករណីនាំចូលក្នុងពេល២៨ថ្ងៃចុងក្រោយ |
| | 2,473,393<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 120,464<br>ករណីសរុប | 3,009<br>ករណីស្លាប់សរុប | 35<br>ករណីនាំចូលពីបរទេសក្នុងរយៈពេល១៤ថ្ងៃចុងក្រោយ |
| **ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩** | 79<br>ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | 145<br>ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | 1,626<br>ចំនួនគ្រែដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល | |

ប្រភពទិន្នន័យ៖ រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ (ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០២១)

## តារាងទី២. ការវាយតម្លៃ[1]អំពីដំណាក់កាលចម្លងតាមខេត្តនីមួយៗ

| ដំណាក់កាលចម្លង | ខេត្ត |
|---|---|
| **ដំណាក់កាលចម្លងទី២** | រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ |
| **ដំណាក់កាលចម្លងទី១** | រាជធានីភ្នំពេញ ខេត្តកោះកុង ខេត្តកែប ខេត្តប៉ៃលិន ខេត្តពោធិសាត់ ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី |

[1] តំណាក់កាលចម្លងសម្រាប់ការចាត់ថ្នាក់កម្រិតថ្នាក់ក្រោមជាតិដោយអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

តារាងទី៣. យុទ្ធនាការចាក់វ៉ាក់សាំងសម្រាប់បុគ្គលិកសុខាភិបាល មនុស្សពេញវ័យ យុវវ័យ និងកុមារ

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | យុវវ័យ និងកុមារ | | |
|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ | អាយុចាប់១២ ឆ្នាំដល់ក្រោម ១៨ឆ្នាំ |
| | (N=43,646) | (N=1,378,688) | (N=10,000,000) | (N=304,317) | (N=1,897,382) | (N=1,827,348) |
| ចាប់ផ្តើម (2021) | 10 កុម្ភៈ | 10 កុម្ភៈ | 10 កុម្ភៈ | 1 វិច្ឆកា | 17 កញ្ញា | 1 សីហា |
| ដូសទី១ | 43,646 (100%) | 1,393,494 (101.1%) | 10,141,514 (101.4%) | 299,265 (98.3%) | 1,994,096 (105.1%) | 1,809,909 (99.0%) |
| ដូសទី២ | 43,646 (100%) | 1,369,756 (99.4%) | 9,785,526 (97.9%) | 213,091 (70.0%) | 1,898,960 (100.1%) | 1,727,979 (94.6%) |
| ដូសទី៣ | 3,392,519 (33.9%) | | | | | |

តារាងទី៤. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩

| ប្រភេទវ៉ាក់សាំងកូវីដ-១៩ | Sinovac | Sinopharm | AstraZeneca (Covishield) | J&J | AstraZeneca (Vaxzevria) | Moderna | Pfizer | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 97 | 78 | 29 | 4 | 1 | 0 | 0 | 209 |
| ចំនួនដូសសរុបបានចាក់ | 19,842,411 | 7,287,438 | 323,344 | 1,053,151 | 1,664,427 | 38,937 | 0 | 30,209,708 |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.49 | 1.07 | 8.97 | 0.38 | 0.10 | 0 | 0 | 0.69 |



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី៥. ការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ និងថ្ងៃលើកបម្រាមវិញ**

| អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ | ស្ថានភាពត្រួតពិនិត្យ | | | | | |
|---|---|---|---|---|---|---|
| | ថ្ងៃទី១នៃការអនុវត្ត | ថ្ងៃកែប្រែចុងក្រោយ | ការអនុវត្ត | | ត្រូវបានលើកដោយផ្នែក | ត្រូវបានលើកទាំងស្រុង |
| | | | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬ ថ្នាក់ក្រោមជាតិ) | ណែនាំឲ្យ ឬតម្រូវឲ្យ | លើកសម្រាប់វិស័យ/ផ្នែកខ្លះ | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ | ១៦ សីហា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ | | មិនទាន់លើកទេ |
| បិទសាលារៀន | ១៦ មិនា ឆ្នាំ២០២០ | ១ វិច្ឆិកា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ | បានលើកហើយ | លើកបម្រាមហើយ |
| បិទកន្លែងធ្វើការ | មិនមានទេ | មិនមានទេ | | | | |
| ការជួបជុំមនុស្សម្នាច្រើន | ៣ មេសា ឆ្នាំ២០២០ | ១២ វិច្ឆិកា ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ | មិនទាន់លើកទេ | មិនទាន់លើកទេ |
| នៅផ្ទះ | មិនមានទេ | មិនមានទេ | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស | ៩ មេសា ឆ្នាំ២០២០ | ២៩ កក្កដា ឆ្នាំ២០២១ | ថ្នាក់ជាតិ | ណែនាំឲ្យ | បានលើកហើយ | បានលើកហើយ |
| ការរឹតបន្តឹងលើការធ្វើដំណើរអន្តរជាតិ | ២៧ មិនា ឆ្នាំ២០២០ | ០៥ ធ្នូ ឆ្នាំ២០២១ | ថ្នាក់ជាតិ | តម្រូវឲ្យ | បានលើកហើយ | បានលើកហើយ |

## ការគាំទ្រដោយអង្គការសុខភាពពិភពលោក

អង្គការសុខភាពពិភពលោក បន្តគាំទ្រក្រសួងសុខាភិបាលនៅក្នុងវិស័យបច្ចេកទេសជាច្រើន ដូចជាផ្តល់យោបល់ផ្នែកបច្ចេកទេសជាភស្តុតាងវិទ្យាសាស្ត្រសម្រាប់បញ្ហាដែលកំពុងកើតមានដូចជាវីរុសកូវីដ-១៩បំប្លែងខ្លួនថ្មីអូមីក្រុងដែលជាវីរុសគួរឱ្យព្រួយបារម្ភ សកម្មភាពតាមដានជំងឺរួមទាំងការតាមដានជំងឺដោយប្រើព័ត៌មានពហុប្រភព និងយុទ្ធសាស្ត្រតាមដានជំងឺសម្រាប់ជំងឺរាតត្បាតកូវីដ-១៩ ការគាំទ្រក្នុងការពិនិត្យឡើងវិញ និងកែប្រែគោលការណែនាំបច្ចេកទេសនានា ការបង្កើត និងចែកចាយវ៉ាក់សាំង ក៏ដូចជាការធ្វើផែនការចែកចាយវ៉ាក់សាំង ហើយនិងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព (ឧទាហរណ៍ ការពង្រឹងការអនុវត្តវិធានការការពារ ការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងអំពីសុវត្ថិភាពវ៉ាក់សាំង) ព្រមទាំងការអនុវត្តយុទ្ធសាស្ត្រស្តីពីការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។

## អភិក្រមយុទ្ធសាស្ត្រ

សម្រាប់ព័ត៌មានស្តីពីអភិក្រមយុទ្ធសាស្ត្រ សូមមើលរបាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ១៩ លេខមុនៗ ចេញមុនថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

## បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

1. **យើងត្រូវតែវិនិយោគនៅថ្ងៃទៅលើការត្រៀមខ្លួនទុកជាមុន ដើម្បីកុំឱ្យយើងមានការសោកស្ដាយនៅថ្ងៃស្អែក។** ការត្រៀមខ្លួនទុកជាមុនរួចរាល់ គឺជាវិធីដ៏ល្អបំផុតក្នុងការកាត់បន្ថយផលវិបាកផ្នែកសុខភាព សេដ្ឋកិច្ច និងសង្គមឱ្យកម្រិតទាបបំផុត។ ជំងឺកូវីដ-១៩ នឹងមិនមែនជាវិបត្តិសុខភាពចុងក្រោយនោះទេ។
2. **យើងត្រូវតែកែប្រែប្រព័ន្ធសុខាភិបាលសម្រាប់ពេលអនាគត។** ប្រព័ន្ធសុខាភិបាលដែលរឹងមាំគឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការគ្រប់គ្រងជំងឺកូវីដ-១៩ និងសម្រាប់ការគ្រប់គ្រងគ្រោះអាសន្នផ្នែកសុខភាពណាមួយនាពេលអនាគត។
3. **យើងត្រូវតែបង្កើតការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មីមួយ។** ជំងឺកូវីដ-១៩ នឹងក្លាយទៅជាជំងឺឆ្លងធម្មតាមួយ។ យើងទាំងអស់គ្នាត្រូវតែសម្របខ្លួនរស់នៅ ធ្វើការ និងទំនាក់ទំនងគ្នាទៅវិញទៅមក តាមរបៀបថ្មីមួយ ហើយនិងរស់នៅជាមួយនឹងមេរោគនេះ។

## ឯកសារយើង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល

របាយការណ៍ស្ដីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្ដីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។

របាយការណ៍ស្ដីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្ដីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។

របាយការណ៍ស្ដីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្ដីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។

គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។

ក្ដារព័ត៌មានឌីជីថលស្ដីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។